**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៩...... សហវ.[illegible]

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមអន្តរាគមន៍ពិសេសក្នុងការទប់ស្កាត់និងបង្រ្កាបអំពើរត់គេចពន្ធ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញលិខិតបញ្ជាលេខ ០១ បប ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងការបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញប្រកាសលេខ ១៦៣ សហវ.ប្រក.អគរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមអន្តរភាគមន៍ពិសេសក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ ដើម្បីបង្កើនប្រសិទ្ធភាពស្រាវជ្រាវ និងបង្ក្រាបបទល្មើសគយ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមបណ្ឌិត **គុណ ញឹម** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- | លោក **ផា អេងឈ័ង** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៣- | លោក **កើត សុទ្ធារ៉ា** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធានប្រចាំការ |
| ៤- | លោក **ទ៉ូ ចណ្ណា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក | សមាជិក |
| ៥- | លោក **គេ សុមុនី** | ប្រធាននាយកដ្ឋានគយនិងរដ្ឋាកររាជធានីភ្នំពេញ | សមាជិក |
| ៦- | លោក **ខៀវ សារឿន** | អនុប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើសទទួលបន្ទុក គ្រប់គ្រងការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ២ | សមាជិក |
| ៧- | លោក **តិច សៀកខន** | អនុប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | សមាជិក |
| ៨- | លោក **ញ៉ៀត សម្បត្តិ** | អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៩- | លោក **ហេ ទិដ្ឋា** | អនុប្រធាននាយកដ្ឋានគយនិងរដ្ឋាកររាជធានីភ្នំពេញ | សមាជិក |
| ១០- | លោក **អ៊ុច តាំងគា** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១១- | លោក លោកស្រីប្រធានសាខាគយនិងរដ្ឋាករទាំងអស់ | | សមាជិក |
| ១២- | លោក **អ៊ុយ រ៉ាស៊ី** | ប្រធានការិយាល័យ នៃនាយកដ្ឋាន គ.រ រាជធានីភ្នំពេញ | សមាជិក |
| ១៣- | លោក **សេង សារឿន** | ប្រធានការិយាល័យ នៃនាយកដ្ឋាន គ.រ រាជធានីភ្នំពេញ | សមាជិក |
| ១៤- | លោក **អ៊ួន សុវណ្ណារ៉ា** | ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ១ | សមាជិក |
| ១៥- | លោក **នុត លីឆួយ** | ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ៣ | សមាជិក |
| ១៦- | លោក **យឹម ចណ្ណា:** | ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ៤ | សមាជិក |
| ១៧- | លោក **ឈួន សោភា** | ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ៥ | សមាជិក |
| ១៨- | លោក **ព្រាប តារ៉ាត់** | ប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ៦ | សមាជិក |
| ១៩- | លោក **ឯម ណារិទ្ធ** | ប្រធានការិយាល័យនាវាចរគយ | សមាជិក |
| ២០- | លោក **ម៉ៅ ធំរ** | ប្រធានការិយាល័យបង្ការបង្ក្រាបបទល្មើសនិងគ្រប់គ្រងផលិតកម្ម | សមាជិក |
| ២១- | លោក **ឈុំ សុភា** | ជំនួយការនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | លេខាធិការ |
| ២២- | លោក **ហោ ស៊ីណាត** | ជំនួយការនាយកដ្ឋានរដ្ឋាករ | លេខាធិការ |
| ២៣- | លោក **ហួង រតនា** | ប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងនៃនាយកដ្ឋានរបបគយ | លេខាធិការ |
| ២៤- | លោក **ឡឹន សំអាត** | អនុប្រធានការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ១ | លេខាធិការ |

**ប្រការ២.-**

ក្រុមអន្តរាគមន៍ពិសេសក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ មានភារកិច្ចដូចតទៅ÷

- កសាងផែនការសកម្មភាពកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគយ
- ស្រាវជ្រាវ ប្រមូលផ្តុំ វិភាគវាយតម្លៃ និងកំណត់មុខសញ្ញាបទល្មើសគយ
- ដឹកនាំកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគយនៅទូទាំងដែនគយនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ក្រុមអន្តរាគមន៍ពិសេសក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ ត្រូវសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ហើយមានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធមកចូលរួមប្រជុំ ឬចូលរួមប្រតិបត្តិការបង្ក្រាបបទល្មើសគយតាមតម្រូវការជាក់ស្តែង។

**ប្រការ៤.-**

សេចក្តីសម្រេចលេខ ០៥៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមអន្តរាគមន៍ពិសេសក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ